# យុវជននយោបាយនៅកម្ពុជា និងអាល្លឺម៉ង់

## ទស្សនៈប្រៀបធៀប

# PARTY YOUTH WINGS IN CAMBODIA AND GERMANY

## A COMPARATIVE PERSPECTIVE

Mr. Johannes Vogel

Konrad
Adenauer
Stiftung

Konrad
Adenauer
Stiftung

**Freedom, justice and solidarity are the basic pricipales underlying the work of the Konrad-Adenauer-Stiftung (KAS). KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian social, conservative and liberal traditions. His name is synonymos with the democratic reconstruction of Germany, the firm alignment of foreign policy with the transatlantic community of values, the vision of the unified Europe and an orientation towards the social market economy. In our European and international cooperation with nealry 80 offices abroad and projects in over 120 countries, we make a unique contribution to the promotion of democracy, the rule of law and a social market economy.**

# យុវជននយោបាយនៅកម្ពុជា និងអាល្លឺម៉ង់

## ទស្សនៈប្រៀបធៀប

លោក ជោហាននេស រ៉ូហ្គែល

Konrad
Adenauer
Stiftung

សេរីភាព យុត្តិធម៌ និងសាមគ្គី ជាគោលការណ៍ក្នុងការកំណត់សកម្មភាពរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) គឺជាមូលនិធិនយោបាយមួយ ដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយគណបក្សប្រជាធិបតេយ្យគ្រឹស្ត (Christian Democratic Union) របស់ប្រទេសអាល្លឺម៉ង់។ លោក ខុនរ៉ាដ អាដិនណៅអ៊ែរ (១៨៧៦-១៩៦៧) គឺជាសហស្ថាបនិកនៃគណបក្ស CDU និងជាអធិការបតីដំបូងគេបង្អស់ នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានបង្រួបបង្រួមពួកសង្គមគ្រឹស្តនិយម ពួកអភិរក្សនិយម និងពួកសេរីនិយមទាំងឡាយ។ កិត្តិនាមរបស់លោក មានន័យដូចគ្នាទៅនឹងការកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ការយល់ស្របគ្នាលើគោលនយោបាយការបរទេស ទៅនឹងគុណតម្លៃនៃសហគមន៍មហាសមុទ្រអាត្លង់ទិក ចក្ខុវិស័យនៃការបង្រួប បង្រួមអឺរ៉ុប និងការតម្រង់ទិសឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសង្គម។ KAS បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើស្ទួយលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសេដ្ឋកិច្ចទីផ្សារសង្គម នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប និងអន្តរជាតិ តាមរយៈការិយាល័យរបស់ខ្លួននៅបរទេសច្រើនជាង ៧០ការិយាល័យ និងមានគម្រោងនានា នៅក្នុងប្រទេសជាង ១២០ប្រទេស។

ការិយាល័យនៅកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៤។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ នៅកម្ពុជា បាននឹងកំពុងបំពេញការងាររបស់ខ្លួនក្នុងវិស័យដូចតទៅ៖ កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ការពង្រឹងគណបក្សនយោបាយ និងសភា កំណែ ទម្រង់ច្បាប់ ការអភិវឌ្ឍប្រព័ន្ធឃោសនា ការអប់រំនយោបាយ និងសេដ្ឋកិច្ចទីផ្សារ សង្គម ក៏ដូចជាការពិគ្រោះយោបល់ផ្នែកគោលនយោបាយការបរទេសផងដែរ។

# មាតិកា


អំពីអ្នកនិពន្ធ ............ ៥

សេចក្ដីផ្ដើម ............ ៧

១. ការរៀបចំ និងរចនាសម្ព័ន្ធចលនាយុវជនគណបក្សដែលបានធ្វើអង្កេត ............ ១២

១.១ ប្រភពដើម និងការវិវឌ្ឍ ............ ១២

១.២ សមាជិកភាពរបស់ស្ថាប័នចលនាយុវជនក្នុងតំបន់ ............ ១៦

១.៣ រចនាសម្ព័ន្ធ និងការចាត់តាំង ............ ១៦

១.៣.១ កម្រិតថ្នាក់ជាតិ ............ ១៧

១.៣.២ ថ្នាក់ក្រោមជាតិ ............ ២៣

១.៤ សមាជិក និងសមាជិកភាព ............ ២៥

១.៤.១ សមាជិកភាពជាឯកតោភាគី និងទ្វេភាគី ............ ២៦

១.៤.២ សិទ្ធ និងកាតព្វកិច្ចរបស់សមាជិក ............ ២៨

២. ក្របខណ្ឌគោលនយោបាយនៃយុវជនគណបក្សនយោបាយដែលត្រូវបានធ្វើការអង្កេត ............ ៣០

២.១ តួនាទីចំពោះគណបក្សមេ ............ ៣១

២.២ ការតាក់តែងគោលនយោបាយផ្ទាល់ខ្លួន ............ ៣២

៣. ការអង្កេតជាក់ស្តែងលើយុវជនគណបក្សនយោបាយ ..... ៣៤
៣.១ ... ក្នុងសភា ..... ៣៥
៣.២ ... នៅក្នុងគណបក្សមេ ..... ៣៦
៣.៣ ... នៅក្នុងសង្គមស៊ីវិល ..... ៣៦
៣.៤. ការផ្សព្វផ្សាយពីគោលនយោបាយ និងកិច្ចការរបស់ខ្លួន ..... ៣៨
៣.៤.១ ការផ្សព្វផ្សាយ និងសារព័ត៌មាន ..... ៣៩
៣.៤.២ បណ្តាញសង្គម ..... ៣៩

សេចក្តីសន្និដ្ឋាន ..... ៤១

ឧបសម្ព័ន្ធ ..... ៤៣
ឧបសម្ព័ន្ធ១៖ ទិដ្ឋភាពរួម នៃចលនាយុវជនគណបក្សនយោបាយ ដែលបានធ្វើការស្រាវជ្រាវ ..... ៤៣
ឧបសម្ព័ន្ធ២៖ គំរូសេចក្តីប្រកាសព័ត៌មាន ..... ៤៤

## អំពីអ្នកនិពន្ធ



ជោហាននេសវ៉ូហ្វែលគឺជានិស្សិតផ្នែកវិទ្យាសាស្ត្រ សង្គម ច្បាប់ និង សេដ្ឋកិច្ច នៃសាកលវិទ្យាល័យ Erfurt។ គាត់មិនត្រឹមតែចាប់អារម្មណ៍លើប្រធានបទ ស្តីពីការអប់រំនយោបាយ និងការចូលរួមរបស់យុវជន ប៉ុណ្ណោះទេ គាត់ថែមទាំងបានចូលរួមយ៉ាងសកម្មក្នុងប្រធានបទនេះទៀតផង។ គាត់ធ្លាប់ជានិស្សិតកម្មសិក្សាការី នៅមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំកម្ពុជា ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ខែកុម្ភៈ ឆ្នាំ២០១៦។

# យុវជននយោបាយនៅកម្ពុជា និងអាល្លឺម៉ង់

## ទស្សនៈប្រៀបធៀប

## សេចក្តីផ្តើម

នៅពេលពិនិត្យមើលតួលេខប្រជាសាស្ត្រកម្ពុជា លក្ខណៈពិសេសមួយ ដែលគួរឲ្យកត់សម្គាល់នោះ គឺចំនួនប្រជាជនប្រហែលពាក់កណ្តាល (នៃប្រជាជនសរុប) មានអាយុក្រោម២៥ឆ្នាំ។[១] ច្បាស់ហើយដែលថា យុវជននឹងត្រូវដើរតួនាទីយ៉ាងសំខាន់តាមវិស័យជាច្រើនក្នុងសង្គមជាតិ នាពេលអនាគត ដោយរួមទាំងវិស័យនយោបាយផងដែរ។ កំណើនមន្ត្រីបក្សនយោបាយជាន់ខ្ពស់ ដែលឆ្លើយតបទៅនឹងអ្នកគាំទ្រសាធារណមតិ តាមបណ្តាញហ្វេសប៊ុក គឺជាសូចនា-ករមួយ បង្ហាញពីការផ្តោតការយកចិត្តទុកដាក់ លើអ្នកបោះឆ្នោតវ័យក្មេង។ ក៏ប៉ុន្តែ ការព្យាយាមរបស់គណបក្ស ក្នុងការទាក់ទាញយុវជន ទៅបោះឆ្នោតឲ្យបក្សរបស់ខ្លួន គឺគ្រាន់តែជាទិដ្ឋភាពមួយជ្រុងតែប៉ុណ្ណោះ (មុខម្ខាងនៃកាក់)។ យុវជនភាគច្រើន មិនត្រឹមតែចង់បោះឆ្នោតឱ្យគណបក្សប៉ុណ្ណោះទេ ពួកគេថែមទាំងចង់ចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនយោបាយ និងរួមចំណែកដល់ការសម្រេចចិត្តនានា ពាក់ព័ន្ធនឹងអនាគតរបស់ខ្លួនទៀតផង។ សញ្ញាណមួយដែលបញ្ជាក់ថាប្រជាជនវ័យក្មេងភាគច្រើន ចង់ចូលរួមកាន់តែសកម្មថែមទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តនោះ គឺការចាប់បដិសន្ធិថ្មីមួយរបស់*គណបក្ស*

១ នេះបើយោងតាមការប៉ាន់ស្មានរបស់ CIA World Factbook ឆ្នាំ ២០១៥, ៥១.១៤% នៃប្រជាជនកម្ពុជាមានអាយុចន្លោះ 0 និង ២៤ ឆ្នាំ។ Cf. Central Intelligence Agency របស់ប្រទេសកម្ពុជា: World Factbook, ០៣.០២.២០១៦, *https://www.cia.gov/library/publications/the-world-factbook/geos/cb.html* (១១.០២.២០១៦) ។

*យុវជនកម្ពុជា (CYP)*។[២] បន្ថែមលើនេះទាំង*គណបក្សប្រជាជនកម្ពុជា (CPP)* និងទាំង*គណបក្សសង្គ្រោះជាតិកម្ពុជា (CNRP)* បានយល់ដឹងពីនិន្នាការនេះ ហើយថែមទាំងបានខិតខំប្រឹងប្រែង បង្កើនការចូលរួមរបស់យុវជនក្នុងជួរគណបក្សរបស់ខ្លួន ដោយបន្តជម្រុញនិងពង្រីកបន្ថែមក្រុមការងារយុវជនគណបក្សរៀងៗខ្លួន។

ត្បិតណាតែ ក្នុងចំណោមប្រជាពលរដ្ឋអាល្លឺម៉ង់៤រូប មានតែ១រូបប៉ុណ្ណោះដែលមានអាយុតិចជាង២៥ឆ្នាំ[៣] ក៏ដោយ ក៏យុវជន*គណបក្សប្រជាធិបតេយ្យគ្រីស្តសាសនិកអាល្លឺម៉ង់ (CDU)*, *គណបក្សសង្គមប្រជាធិបតេយ្យអាល្លឺម៉ង់ (SPD)*, *គណបក្សសម្ព័ន្ធភាព* និង*ឆ្វេងនិយម ៩០ Green*[៤] បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងនយោបាយ របស់ប្រទេសមួយនេះ។ ក្នុងជួរគណបក្សមេ យុវជន ត្រូវបានគេអោយតម្លៃជាពិសេសថាជា៖

- ក្រុមប្រឹក្សាយោបល់ ឬធនាគារខួរក្បាល (Think Tank) សម្រាប់បណ្តុះគំនិតថ្មីៗ
- វេទិកាលើកកម្ពស់ / ជម្រុញអ្នកនយោបាយវ័យក្មេងដែលមានទេពកោសល្យ
- មូលដ្ឋានគាំទ្រវ័យក្មេងនិងស្វាហាប់ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត។

ប៉ុន្តែភាពពាក់ព័ន្ធរបស់យុវជនទាំងនេះ មានវិសាលភាពច្រើនជាងអ្វីដែល

---

២ Cf. e. g. Chea Takihiro គណបក្សយុវជនកម្ពុជា ក្នុងកាសែត: Khmer Times ២៤.១២.២០១៥, *http://www.khmertimeskh.com/news/19111/cambodian-youth-party/* (១៧.០២.២០១៦) និងឡាយ សាមាន, សមាជិកចូលថ្មី យុវជនគណបក្សយុវជន នៅក្នុង: ភ្នំពេញប៉ុស្តិ៍ ១៧.០២.២០១៦, *http://www.phnompenhpost.com/national/new-youthparty-signed-being* (១៧.០២.២០១៦)

៣ នេះបើយោងតាមការប៉ាន់ស្មានរបស់ CIA World Factbook ឆ្នាំ ២០១៥, ២៣.១៦% នៃចំនួនប្រជាជនអាល្លឺម៉ង់ មានអាយុចន្លោះ 0 និង ២៤ឆ្នាំ។ Cf. Central Intelligence Agency របស់អាល្លឺម៉ង់ World Factbook0៥.0១.២០១៦, *https://www.cia.gov/library/publications/the-world-factbook/geos/gm.html* (១១.0២.២០១៦)។

៤ German: *Christlich Demokratische Union (CDU), Sozialdemokratische Partei Deutschlands (SPD), Die Linke* and *Bündnis 90/Die Grünen.*

បានរៀបរាប់ខាងលើនេះទៅទៀត ពោលគឺយុវជនគណបក្ស ក៏អាចជាស្ពានតភ្ជាប់ដ៏សំខាន់ផងដែរ រវាងប្រព័ន្ធនយោបាយ និងសង្គមស៊ីវិល ពិសេសតាមរយៈការផ្តល់ឱកាសឱ្យយុវជនបញ្ចេញសម្លេងទាក់ទងនឹងការសម្រេចចិត្តនានាលើអនាគតរបស់ខ្លួន។ តាមកិច្ចការនេះ យុវជន អាចផ្តល់ការគាំទ្រដូចជា៖

- ផ្សព្វផ្សាយពីផលប្រយោជន៍នយោបាយ និងការចូលរួមរបស់យុវជន
- ការពារភាពជ្រុលនិយម និងភាពដាច់ខាតនៃនយោបាយដែលមានសក្តានុពលនានា
- និរន្តរភាពនៃប្រព័ន្ធប្រជាធិបតេយ្យទាំងមូល។

ដើម្បីផ្តល់នូវទស្សនៈប្រៀបធៀប រវាងយុវជនគណបក្សក្នុងប្រទេសកម្ពុជា និងប្រទេសអាល្លឺម៉ង់ ក៏ដូចជាបង្ហាញពីទិដ្ឋភាពទូទៅ និងលក្ខណៈពិសេសដាច់ដោយឡែក និងពីលទ្ធភាពជាច្រើន សម្រាប់យុវជនចូលរួមក្នុងវិស័យនយោបាយផងដែរនោះ ការសិក្សាមួយនេះ នឹងពិនិត្យមើលអោយបានលម្អិតតែទៅលើយុវជនគណបក្ស ដែលបានជាប់ឆ្នោតនៅក្នុងសភាជាតិនៃប្រទេសទាំងពីរទេ។ ព័ត៌មានក្នុងឯកសារ ក៏ដូចជាក្នុងការសិក្សានេះ ត្រូវបានប្រមូលចងក្រងតាមរយៈការសម្ភាសន៍ និងការសាកសួរ ផ្លាស់ប្តូរតាមរយៈសារអេឡិចត្រូនិចជាមួយតំណាងយុវជនបក្សនយោបាយ។[៥] ក្នុងនោះ ក៏មានការចូលរួមផ្តល់នូវព័តមានត្រលប់ល្អៗពីក្រុមការងារនៅមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរប្រចាំកម្ពុជាផងដែរ។

**យុវជនគណបក្សដែលត្រូវបានធ្វើការអង្កេតរួមមាន៖**

- ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា (CPP)
- ក្រុមយុវជនរបស់គណបក្សសង្គ្រោះជាតិកម្ពុជា (CNRP)

៥ គួរកត់សម្គាល់ផងដែរថា ទាក់ទងទៅនឹងក្រុមការងារយុវជន*គណបក្សប្រជាជនកម្ពុជា* និង*គណបក្សសង្គ្រោះជាតិ* ការចូលរួមរបស់យុវជននៅកម្ពុជា គឺនៅតែក្នុងដំណាក់កាលវិវត្តន៍។ ព័ត៌មានដែលបង្ហាញក្នុងអត្ថបទនេះ គឺសំដៅត្រឹម*ខែកុម្ភៈ ឆ្នាំ២០១៦* ប៉ុណ្ណោះ។

**និងមកពីប្រទេសអាល្លឺម៉ង់៖**

- សហភាពយុវជនអាល្លឺម៉ង់[៦] របស់
  *គណបក្សសហភាពប្រជាធិបតេយ្យគ្រីស្តសាសនិកអាល្លឺម៉ង់ (CDU)*
- យុវជនសង្គមនិយម SPD[៧] របស់
  *គណបក្សសង្គមប្រជាធិបតេយ្យអាល្លឺម៉ង់ (SPD)*
- យុវជនឆ្វេងនិយម[៨] របស់
  *គណបក្សឆ្វេងនិយម*
- យុវជនបៃតង[៩] នៃ
  *សម្ព័ន្ធភាព ៩០/* Green។

**ការសិក្សានេះ ត្រូវបានរៀបចំឡើងដូចខាងក្រោម**

**ជំពូកទី ១៖ ការរៀបចំ និងរចនាសម្ព័ន្ធចលនាយុវជនដែលបានធ្វើការអង្កេត**

- តើវិវឌ្ឍន៍របស់ចលនាយុវជនគណបក្សទាំង៦ខាងលើ មានសភាពយ៉ាងដូចម្តេច?
- តើពួកគេជាសមាជិក របស់អង្គការចាត់តាំងតំបន់ណាមួយ (អាស៊ី ឬអឺរ៉ុប)?
- តើរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ពួកគេ ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ មានសភាពដូចម្តេចដែរ?
- តើអ្នកណាខ្លះជាសមាជិករបស់ពួកគេ ហើយមានសិទ្ធិនិងភារកិច្ចដូចម្តេចខ្លះ?

**ជំពូកទី ២៖ ក្របខណ្ឌគោលនយោបាយចលនាយុវជនដែលបានធ្វើការអង្កេត**

---

៦ អាល្លឺម៉ង់៖ *សហភាពយុវជនអាល្លឺម៉ង់ (Junge Union Deutschlands)* ដែលតទៅហៅថា *សហភាពយុវជន*។

៧ អាល្លឺម៉ង់: *Arbeitsgemeinschaft der und Jungsozialisten und Jungsozialistinnen in der SPD ដែលតទៅហៅថា យុវជនសង្គមនិយម*។

៨ អាល្លឺម៉ង់: *linksjugend [ ប្រកាន់តឹង]* ដែលតទៅហៅថា *យុវជនឆ្វេងនិយម*។

៩ អាល្លឺម៉ង់: *Grüne Jugend*

- តើយុវជនគណបក្សទាំង៦ យល់ឃើញយ៉ាងដូចម្តេចអំពីតួនាទីរបស់ខ្លួនក្នុងគណបក្សមេ?
- តើពួកគេបានរៀបចំគោលនយោបាយរបស់ខ្លួនដែរឬទេ? ប្រសិនបើមានមែន តើធ្វើដូចម្តេច?

ជំពូកទី ៣: ការអង្កេតជាក់ស្តែងលើយុវជនគណបក្សនយោបាយ

- តើយុវជនគណបក្ស អនុវត្តគោលនយោបាយរបស់ខ្លួននៅកន្លែងណា?
- តើពួកគេធ្វើការនៅក្នុងសភា គណបក្សមេ និងសង្គមស៊ីវិលយ៉ាងដូចម្តេច?
- តើពួកគេបានលើកកម្ពស់ ផ្សព្វផ្សាយគោលនយោបាយនិងការងាររបស់ខ្លួន តាមរយៈកាសែត ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គមយ៉ាងដូចម្តេច?

ឯកសារនេះ បញ្ចប់ដោយសេចក្តីសន្និដ្ឋានខ្លីមួយ។ តារាងទិដ្ឋភាពរួម នៃការសិក្សាស្ទង់មតិលើយុវជនបក្សទាំង ៦ និងគំរូសំណាក នៃសេចក្តីប្រកាសព័ត៌មាន មានភ្ជាប់ជាឧបសម្ព័ន្ធនៅខាងក្រោយ។

# ១. ការរៀបចំ និងរចនាសម្ព័ន្ធចលនាយុវជនគណបក្ស ដែលបានធ្វើអង្កេត

ជំពូកនេះ នឹងពិនិត្យមើលលើអង្គការចាត់តាំង ការរៀបចំ និងរចនាសម្ព័ន្ធនៃក្រុមយុវជនគណបក្សទាំង៦ ព្រមទាំងប្រវត្តិដើមរបស់ខ្លួនតាមលំដាប់លំដោយ។ យើងនឹងជជែកដោយសង្ខេបផងដែរ អំពីសមាជិកភាពនៅក្នុងរចនាសម័ន្ធអង្គការក្នុងតំបន់ (អាស៊ី ឬអឺរ៉ុប) ក្នុងគោលដៅស្រដៀងគ្នានេះផងដែរ។ ចំណុចចុងក្រោយ នឹងបរិយាយ អំពីរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ក្រុមយុវជនបក្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាទិដ្ឋភាពរួមពីសមាជិកភាព សិទ្ធិ និងភារកិច្ច ដែលត្រូវបានផ្តល់ឱ្យ។

## ១.១ ប្រភពដើម និងការវិវឌ្ឍ

ក្រុមការងារយុវជនគណបក្ស ដែលបានធ្វើអង្កេតទាំង ៦ក្រុម ឆ្លងកាត់ការវិវឌ្ឍផ្សេងៗគ្នា។ ដើម្បីស្វែងយល់ពីមុខងារ និងរចនាសម្ព័ន្ធក្រុមការងារទាំងនេះអោយបានត្រឹមត្រូវ គឺជាការចាំបាច់ ដែលត្រូវពិចារណា អំពីលក្ខខណ្ឌក៏ដូចជាស្ថានភាពនៃការចាប់កំណើត និងការវិវឌ្ឍនៃក្រុមការងារយុវជនទាំងនោះសិន។ ខណៈដែលក្រុមយុវជនបក្សមួយចំនួន មានប្រវត្តិចាស់ជាង១០០ឆ្នាំមកហើយ ក្រុមខ្លះទៀតទើបតែត្រូវបានបង្កើតឡើងតែក្នុងរយៈពេលពីរបីឆ្នាំមុនប៉ុណ្ណោះ។

*យុវជនសង្គមនិយម* គឺជាក្រុមយុវជន ដែលមានប្រវត្តិចាស់ជាងគេ ក្នុងចំណោមក្រុមយុវជនបក្ស ដែលបានចូលរួមអង្កេត។ ក្រុមនេះ បានកកើតឡើងនៅឆ្នាំ១៩០៤ ក្រោយមរណភាពរបស់អ្នកហាត់ការវ័យក្មេងមួយរូប។ ជាពេលដែលសមាគមយុវកម្មករដំបូង[១០] ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ែកឡាំង។

១០ German: Arbeiterjugendverein.

រដ្ឋអំណាចបានហាមប្រាម មិនអោយមានអង្គការនយោបាយយុវជនឡើយនៅពេលនោះ ជាហេតុធ្វើអោយគេដាក់បញ្ចូល អតីត*យុវជនសង្គមនិយម* ឯករាជ្យទៅក្នុងរចនាសម្ព័ន្ធបក្ស *SPD* ក្នុងឆ្នាំ១៩០៨។ បើទោះជាដូចនេះក្តី ដោយសារជំលោះផ្ទៃក្នុងគណបក្សមេបានរំលាយ *យុវជនសង្គមនិយម* នៅក្នុងឆ្នាំ ១៩៣១។ ក្រោយសង្គ្រាមលោកលើកទីពីរ វាត្រូវបានបង្កើតឡើងវិញម្តងទៀតក្នុងក្របខណ្ឌជាក្រុមការងាររបស់ *SPD* នៅក្នុងឆ្នាំ ១៩៤៦។ នៅឆ្នាំ ១៩៦៩ *យុវជនសង្គមនិយម* បានសម្រេចចិត្តប្រឡូកក្នុងការងារសង្គមស៊ីវិលអោយបានកាន់តែខ្លាំងក្លា និងបង្កើតគោលនយោបាយផ្ទាល់ខ្លួន។[១១]

មួយឆ្នាំមុនពេលបង្កើតឡើងវិញនៃ*យុវជនសង្គមនិយម* ក្នុងឆ្នាំ ១៩៤៥ ស្ថាប័ននាំមុខរបស់*សហភាពយុវជន* ពោលគឺសមាគមយុវជនអាល្លឺម៉ង់ និង*កម្លាំងវ័យក្មេងរបស់ CDU*[១២] ត្រូវបានបង្កើតឡើង។ *សហភាពយុវជន* ថ្នាក់ជាតិត្រូវ បានបង្កើតឡើងក្នុងឆ្នាំ ១៩៤៧ រួមជាមួយការបង្កើតឡើងនូវក្រប-ខណ្ឌសហព័ន្ធ ដោយមានការទទួលស្គាល់ជាផ្លូវការថា ជាក្រុមយុវជនឯករាជ្យរបស់គណបក្ស *CDU* តាមក្រោយមកទៀតក្នុងឆ្នាំ ១៩៥០។[១៣]

*ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* បែកចេញពី *សម្ព័ន្ធយុវជនបដិវត្តន៍ប្រជាជនកម្ពុជា* ដែលត្រូវបានបង្កើតឡើង ដើម្បីរួបរួមកម្លាំងប្រឆាំងនឹងខ្មែរក្រហមក្នុងឆ្នាំ ១៩៧៨ ដែលបច្ចុប្បន្ននេះ ត្រូវបានស្គាល់ថាជា*សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC)*។ បន្ទាប់ពីការប្តូរឈ្មោះរបស់ *បក្សបដិវត្តន៍ប្រជាជនខ្មែរ* ទៅជា*គណបក្សប្រជាជនកម្ពុជា (CPP)* ក្នុងឆ្នាំ១៩៩១មក ការចូលរួមរបស់យុវជន ត្រូវបានប្បញ្ញត្តិជាផ្លូវការនៅក្នុងឯកសារផ្ទៃក្នុង ដោយគណៈកម្មាធិការកណ្តាលរបស់គណបក្សក្នុងឆ្នាំ២០០៩។ មុនពេលនេះ ការចូលរួម

---

១១ Cf. i. a. Jusos Hessen Süd, Eine kurze Geschichte der Jusos, http://jusos-hs.de/eine-kurze-geschichte-der-jusos (15.02.2016) and Jusos Tübingen, Geschichte der Jusos, http://www.jusos-tuebingen.de/mitmachen/geschichte-der-jusos/ (15.02.2016).

១២ German: *Junge Aktion* and *Arbeitsgemeinschaft junger Deutscher in der CDU*.

១៣ Cf. i. a. Junge Union Deutschlands, Die Geschichte der JUNGEN UNION seit 1945, http://www.junge-union.de/ueber-uns/geschichte/ (15.02.2016).

របស់យុវជនភាគច្រើន ត្រូវបានកំណត់ដោយច្បាប់ទម្លាប់ តែប៉ុណ្ណោះ។

ក្រោយការចាក់គ្រឹះនៃអង្គការយុវជនថ្នាក់ក្រោមជាតិជាច្រើនពីឆ្នាំ ១៩៨៨ រហូតដល់ឆ្នាំ ១៩៩១ សហព័ន្ធយុវជនជម្រើសបៃតង[១៤] ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤។ វាបានប្តូរឈ្មោះរបស់ខ្លួនទៅជា *យុវជនបៃតង* នៅឆ្នាំ ២០០០ និងបានក្លាយជាសម្ព័ន្ធយុវជនឯករាជ្យផ្លូវការ *'90 Green* ក្រោយនោះមួយឆ្នាំពោលគឺនៅក្នុងឆ្នាំ២០០១។[១៥]

*ចលនាយុវជនឆ្វេងនិយម* គឺជាក្រុមអ្នកស្នងរបស់អង្គការយុវជនជាច្រើន ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩០ ដោយមានទំនាក់ទំនងជាមួយនឹង គណបក្ស *ពលករនិងយុត្តិធម៌សង្គម តាមរយៈការបោះឆ្នោតជាជម្រើសជំនួស (WASG)* និង *បក្សសង្គមនិយម ប្រជាធិបតេយ្យ (PDS)*[១៦]។ អ្វីដែលជាចំណុចពិសេសនោះគឺ *[ការប្រកាន់មាំរបស់]ចលនាយុវជនសង្គមនិយម*[១៧] ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩។ *យុវជនឆ្វេងនិយម* នេះត្រូវបានបានបង្កើតឡើងមួយខែមុនពេលច្របាច់បញ្ចូលគ្នារវាង *WASG* និង *PDS* ដែលបាន ក្លាយជា *ក្រុមឆ្វេងនិយម* នៅក្នុងឆ្នាំ២០០៧។ ក្រុមនេះ បានឡើងមកជំនួសក្រុមយុវជនឯករាជ្យចាស់ របស់គណបក្សបង្កើតថ្មី។[១៨]

ចលនាយុវជនបក្សក្មេងបំផុត ក្នុងចំណោមក្រុមយុវជនបក្សទាំង៦នេះ គឺ *យុវជនគណបក្សសង្គ្រោះជាតិ* ដែលជាបក្សត្រូវបានបង្កើតឡើង បន្ទាប់ពីមានការច្របាច់បញ្ចូលគ្នានៃ *គណបក្សសមរង្ស៊ី (SRP)* និង*គណបក្សសិទ្ធិមនុស្ស (HRP)* និងការបង្កើត*គណបក្សសង្គ្រោះជាតិកម្ពុជា (គណបក្សសង្គ្រោះជាតិ)* នៅក្នុងឆ្នាំ២០១៣ មក។ នៅឆ្នាំដដែលនេះដែរ *គណបក្សសង្គ្រោះជាតិ* បានធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងបានបង្កើតជាក្រុមយុវជន *គណ-*

១៤ German: *Grün-Alternatives Jugendbündnis*

១៥ Cf. i. a. Grüne Jugend, Geschichte, https://gruene-jugend.de/geschichte/ (15.02.2016).

១៦ German: *Arbeit & soziale Gerechtigkeit - Die Wahlalternative (WASG)* and *Partei des Demokratischen Sozialismus (PDS).*

១៧ German: *['solid] - die sozialistische Jugend.*

១៨ Cf. i. a. Linksjugend Solid, Verbandsgeschichte, https://www.linksjugend-solid.de/verband/verbandsgeschichte/ (15.02.2016).

*បក្សសង្គ្រោះជាតិ* នៅថ្នាក់ជាតិ។ ដើមឡើយ វាត្រូវបានគេរៀបចំជាចលនាមហាជន ដែលស្ថិតនៅក្រោមនាយកដ្ឋាន កិច្ចការសាធារណៈរបស់គណបក្សនេះ ជាក្រុមការងារមួយស្ថិតនៅក្រោមបង្គាប់ប្រធាន និងអនុប្រធានបក្សដោយផ្ទាល់។

ឈរលើការប្រៀបធៀបមូលដ្ឋានគ្រឹះ និងការវិវឌ្ឍនៃយុវជនបក្សដោយពិនិត្យលើចំណុចស្រដៀងគ្នាជាច្រើន ក៏ដូចជាភាពខុសគ្នា ផ្អែកតាមបរិបទប្រវត្តិសាស្ត្រនីមួយៗ មានចំណុចពីរផុសចេញយ៉ាងច្បាស់ ដែលបង្ហាញពីភាពខុសប្លែកគ្នារវាងយុវជនបក្សកម្ពុជា និងយុវជនបក្សអាល្លឺម៉ង់៖

i. ខណៈដែល *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា* និង *គណបក្សសង្គ្រោះជាតិកម្ពុជា* ត្រូវបានបង្កើតឡើង ដោយគណបក្សមេ *យុវជនសង្គមនិយម* និង *យុវជនបៃតង* គឺដើមឡើយឯករាជ្យទាំងស្រុង ហើយក្រោយមកបានក្លាយជាចលនាយុវជនបក្សផ្លូវការរបស់គណបក្សមេ។ *សហភាពយុវជន* និង *យុវជនឆ្វេងនិយម* បិតនៅជាប់ជាមួយនឹង គណបក្សមេរបស់ពួកគេរៀងៗខ្លួន ឬបន្តតំណែងមុនរបស់ខ្លួន ប៉ុន្តែចលនាទាំងនេះដើមឡើយត្រូវបានគេបង្កើតឡើងជាស្ថាប័នដាច់ដោយឡែក និងផ្តួចផ្តើមដោយយុវជនខ្លួនឯង។

ii. ខណៈដែល *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា* និង *គណបក្សសង្គ្រោះជាតិកម្ពុជា* ដំបូងឡើយ ពឹងលើរចនាសម្ព័ន្ធថ្នាក់ជាតិ ហើយបច្ចុប្បន្ននេះ កំពុងពង្រីករចនាសម្ព័ន្ធរបស់ខ្លួនទៅថ្នាក់ក្រោមជាតិនោះ *សហភាពយុវជន យុវជនសង្គមនិយម យុវជនឆ្វេងនិយម* និង *យុវជនបៃតង* មានប្រភពដើមពីកម្រិតថ្នាក់ក្រោមជាតិ ដែលក្រោយមកបានអភិវឌ្ឍរចនាសម្ព័ន្ធរបស់ខ្លួនមកថ្នាក់ជាតិ។

## ១.២ សមាជិកភាពរបស់ស្ថាប័នចលនាយុវជនក្នុងតំបន់

ក្នុងចំណោមយុវជនបក្សទាំងអស់ ដែលបានស្ទង់មតិ បានបង្ហាញពីការចាប់អារម្មណ៍ ជាពិសេសមិនត្រឹមតែ នៅក្នុងនយោបាយជាតិ ប៉ុណ្ណោះទេ ថែមទាំងការអភិវឌ្ឍក្នុងតំបន់ទៀតផង។ *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* និង *គណបក្សសង្គ្រោះជាតិកម្ពុជា* កំពុងរៀបចំបង្កើតអោយមានទំនាក់ទំនង នៅកម្រិតអាស៊ី ដោយក្នុងនោះក្រុមយុវជន*គណបក្សសង្គ្រោះជាតិកម្ពុជា* បានបញ្ជូនតំណាងទៅចូលរួមកិច្ចប្រជុំយុវជនរបស់ ក្រុមប្រឹក្សាសេរី និង*ប្រជាធិបតេយ្យអាស៊ី (CALD)*។ យុវជនបក្សអាល្លឺម៉ង់ចំនួនបួនក្រុម គឺស្ថិតនៅក្រោមឆ័ត្រស្ថាប័នអឺរ៉ុបដូចជាសហភាពយុវជន ជាសមាជិកនៃ*យុវជនគណបក្សប្រជាជនអឺរ៉ុប (YEPP) យុវជនសង្គមនិយមជាសមាជិកនៃ យុវជនសង្គមនិយមអឺរ៉ុប (YES) យុវជនឆ្វេងនិយម* ជាសមាជិកនៃ *បណ្តាញយុវជនប្រជាធិបតេយ្យអឺរ៉ុបនិយមឆ្វេង (ENDYL)* និង*យុវជនបៃតង* ជាសមាជិកនៃ*សហព័ន្ធយុវជនបៃតងអឺរ៉ុប (FYEG)*។ ស្ថាប័នឆ័ត្រទាំងនេះ មិនត្រឹមតែជួយយុវជនបក្សឱ្យចងបណ្តាញ និង ផ្លាស់ប្តូរបទពិសោធន៍ និងការអនុវត្តល្អ ជាមួយស្ថាប័នស្រដៀងគ្នានៅក្នុងប្រទេសផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ជួយឱ្យពួកគេ ដោះស្រាយបញ្ហាក្នុងតំបន់រួមគ្នាផងដែរ

## ១.៣ រចនាសម្ព័ន្ធ និងការចាត់តាំង

ចំណុចខុសគ្នាចំបង នៃរចនាសម្ព័ន្ធយុវជនបក្សទាំងប្រាំមួយ មិនអាស្រ័យលើស្ថានភាពនៃការបង្កើតមុនឬ ក្រោយ (សូមមើលជំពូក ១.១) របស់យុវជនបក្សកម្ពុជានិងយុវជនបក្សអាល្លឺម៉ង់នោះទេ៖ *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិកម្ពុជា* និង*យុវជនសង្គមនិយម* ត្រូវបានរៀបចំឡើងជាផ្នែកមួយ និងជាក្រុមការងារបង្អែករបស់គណបក្សមេ។ ផ្ទុយទៅវិញ *សហភាពយុវជន យុវជនឆ្វេងនិយម* និង*យុវជនបៃតង* ជានីតិបុគ្គលឯករាជ្យ

មានឯកសារត្រឹះផ្ទាល់ខ្លួន។ ទោះជាយ៉ាងណា ការប្រព្រឹត្តទៅនៃការ *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិកម្ពុជា* និង *យុវជនសង្គមនិយម* ស្ថិតនៅក្រោមការគ្រប់គ្រង កំណត់ដោយគោលការណ៍ជាលាយលក្ខណ៍អក្សរ។ បើទោះជាដូចនេះក្តី កិច្ចការទាំងនេះមិនត្រូវបានអនុម័តដោយយុវជនបក្សខ្លួនឯងផ្ទាល់ទេ ប៉ុន្តែស្ថិតក្រោមអំណាចនៃគណបក្សមេរបស់ពួកគេ។

លក្ខណៈរួមមួយរបស់ក្រុមយុវជនបក្សដែលបានស្ទង់មតិ នោះគឺថាពួកគេមានទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ។ ចំនួននៅថ្នាក់ក្រោមជាតិ មានភាពខុសគ្នា៖ ខណៈដែល *យុវជនសង្គមនិយម* មាន ៥កម្រិត នៅថ្នាក់ក្រោមជាតិ *យុវជនគណបក្សសង្គ្រោះជាតិកម្ពុជា* និង *សហភាពយុវជន* មានបួនកម្រិត *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា* និង *យុវជនបៃតង* មានបីកម្រិត និង *យុវជនឆ្វេងនិយម* មានពីរកម្រិត។ ភាពខុសគ្នា មិនត្រឹមតែទៅនឹងទំហំផ្សេងគ្នានៃ ក្រុម យុវជន បក្សទេ ប៉ុន្តែភាគច្រើនគឺភាពស្រដៀងគ្នាទៅនឹងរចនាសម្ព័ន្ធបក្សមេបន្ថែម។

## *១.៣.១ កម្រិតថ្នាក់ជាតិ*

បើទោះជាតាមការស្ទង់មតិនោះរកឃើញថា យុវជនបក្សខ្លះ ដើរតួនាទីជាក្រុមការងារបង្អែកនៅក្នុងបក្សមេ ហើយក្រុមខ្លះ ទៀតមានលក្ខណៈឯករាជ្យជាង កំណត់សម្គាល់ស្ថាប័នមួយចំនួន ត្រូវបានរកឃើញនៅកម្រិតថ្នាក់ជាតិក្នុងក្រុមយុវជន បក្សភាគច្រើន៖

- មហាសន្និបាត ឬសន្និបាតប្រតិភូ ធ្វើការសម្រេចចិត្តលើបញ្ហាសំខាន់ៗ ដូចជា ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការគ្រប់គ្រង និងបង្កើតអង្គនីតិបញ្ញត្តិផ្ទៃក្នុងរបស់ស្ថាប័ន
- គណៈកម្មាធិការគ្រប់គ្រង ទទួលខុសត្រូវលើការងារប្រចាំថ្ងៃ និងបង្កើតអង្គនីតិប្រតិបត្តិផ្ទៃក្នុងស្ថាប័ន

- តំណាងនៅថ្នាក់ក្រោមជាតិ ជាក្រុមប្រឹក្សាយោបល់ ជូនគណៈកម្មាធិ-ការគ្រប់គ្រង
- គណៈកម្មាធិការជំនាញ ផ្តល់ការគាំទ្រ ធ្វើការលើបញ្ហាជាក់លាក់

- ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាស្ថាប័នឯករាជ្យ ដែលដោះស្រាយជម្លោះផ្ទៃក្នុង និងបង្កើតអង្គភាពតុលាការក្នុងស្ថាប័ន។

បើទោះបីជាដូចនេះក៏ដោយ ឈ្មោះពិតប្រាកដ តួនាទីនិងភារកិច្ចរបស់ស្ថាប័នទាំងនេះគឺមានភាពខុសគ្នាពីក្រុមយុវជនបក្សមួយទៅបក្សមួយទៀត។

រចនាសម្ព័ន្ធសាមញ្ញបំផុត នៅថ្នាក់ជាតិរបស់ *ក្រុមយុវជនគណបក្សសង្គ្រោះជាតិ* គឺៈ វាមានក្រុមការងារយុវជន ថ្នាក់ជាតិតែមួយគត់ ដែលតែងតាំងដោយប្រធានគណបក្សមេ។ ដោយសារតែទំហំនេះមានកំណត់ ក្រុមការងារនេះ មិនមានរចនាសម្ព័ន្ធខាងក្នុងណាមួយបន្ថែមទៀតទេ។[១៩]

*ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជាថ្នាក់ជាតិ* មានក្រុមការងារយុវ-ជនមជ្ឈឹម តែងតាំងដោយគណបក្សមេ និងស្ថិតនៅក្រោមបង្គាប់របស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ក្រៅពីសមាជជាតិ ក្រុមការងារយុវជនមជ្ឈឹម ក៏មានគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្រុមការងារប្រាំផ្នែកផ្សេងទៀត ទទួលបន្ទុកបញ្ហាជាក់លាក់។

១៩ បច្ចុប្បន្ននេះ គណបក្សសង្គ្រោះជាតិ កំពុងតែធ្វើផែនការកំណែទម្រង់ស្ថាប័នចលនាយុវជនបក្ស។ ក្នុងន័យនេះ គណបក្សសង្គ្រោះជាតិ មានចេតនានឹងបង្កើតក្រុមប្រឹក្សាយុវជនមួយក្រុមក្នុងបក្សរបស់ខ្លួន ដោយមានតំណាង ៥០រូបមកពីបណ្តាខេត្តទាំង ២៥ (២រូបក្នុងមួយខេត្ត) និង៥០រូបផ្សេងទៀតតែងតាំងដោយគណៈកម្មាការអចិន្ត្រៃយ៍គណបក្ស។ ក្រុមប្រឹក្សាយុវជនថ្មីនេះ នឹងក្លាយជាស្ថាប័នតាក់តែងច្បាប់នៃចលនាយុវជនបក្សសង្គ្រោះជាតិ ដោយអនុលោមទៅតាម បទបញ្ជា និងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន។ ជាងនេះទៅទៀត ក៏មានផែនតម្រូវឲ្យក្រុមប្រឹក្សាយុវជនធ្វើការបោះឆ្នោតជ្រើសរើស"ក្រុមប្រឹក្សាប្រតិបត្តិ" ដែលមានសមាសភាពចំនួន ២០រូប ដើម្បីគ្រប់គ្រងសកម្មភាពប្រចាំថ្ងៃ។ កំណែទម្រង់នេះ នឹងលេចចេញជារូបរាង នៅចុងឆ្នាំ ២០១៦។

*រូបភាពទី១៖ ស្ថាប័នជាតិរបស់ក្រុមយុវជនគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា*

| | **យុវជនគណបក្សប្រជាជនកម្ពុជា** | **យុវជនគណបក្សសង្គ្រោះជាតិ** |
|---|---|---|
| មហាសន្និបាត/សន្និបាទប្រតិភូ | ក្រុមការងារយុវជនថ្នាក់ជាតិ *សមាជិក ៥ រូប* | ក្រុមការងារយុវជនមជ្ឈឹម *សមាជិក ៦៥ រូប* |
| គណៈកម្មាធិការគ្រប់គ្រង | -- | គណៈកម្មាធិការអចិន្ត្រៃយ៍ *សមាជិក ១៥-២០រូប* |
| តំណាងថ្នាក់ក្រោមជាតិ | -- | -- |
| គណៈកម្មាការជំនាញ | -- | គណៈកម្មាធិការអចិន្ត្រៃយ៍ *សមាជិក ១៥-២០រូប* |
| ក្រុមប្រឹក្សាអាជ្ញាកណ្តាល | -- | |

អង្គភាពរបស់ *យុវជនសង្គមនិយម* នៅកម្រិតថ្នាក់សហព័ន្ធ រួមមានសន្និបាតប្រតិភូ គណៈកម្មាធិការគ្រប់គ្រង តំណាងថ្នាក់ក្រោមជាតិ ជាក្រុមប្រឹក្សាយោបល់ និងគណៈកម្មាធិការជំនាញផ្សេងទៀត ធ្វើការលើបញ្ហាជាក់លាក់។

*យុវជនឆ្វេងនិយម* មានសន្និបាតប្រតិភូ គណៈកម្មាធិការគ្រប់គ្រងតំណាងថ្នាក់ក្រោមជាតិជាអង្គភាពត្រួតពិនិត្យ ទៅលើគណៈកម្មាធិការគ្រប់គ្រង គណៈកម្មាធិការជំនាញឯករាជ្យជាច្រើនផ្សេងទៀត ទទួលបញ្ហាជាក់លាក់ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល។ បន្ថែមពីនេះទៀតក្រុមនិស្សិតសាកលវិទ្យាល័យរបស់ខ្លួន *(The Left.SDS)* ត្រូវបានរៀបចំជា ក្រុមការងារសហព័ន្ធ។

*រូបភាពទី២៖ ស្ថាប័នជាតិរបស់យុវជនសង្គមនិយម និងយុវជនឆ្វេងនិយម*

| | **យុវជនសង្គមនិយម** | **យុវជនឆ្វេងនិយម** |
|---|---|---|
| មហាសន្និបាត/<br>សន្និបាតប្រតិភូ | សន្និសិទសហព័ន្ធ<br>*ប្រតិភូចំនួន ៣០០ នាក់* | សភាសហព័ន្ធ<br>*ប្រតិភូ ២៥០ នាក់* |
| គណៈកម្មាធិការគ្រប់គ្រង | ក្រុមប្រឹក្សាភិបាលសហព័ន្ធ<br>*សមាជិក ៩ រូប* | ក្រុមប្រឹក្សាអ្នកនាំពាក្យសហព័ន្ធ *សមាជិក ៧ រូប* |
| តំណាងថ្នាក់ក្រោមជាតិ | គណៈកម្មាធិការសហព័ន្ធ<br>*សមាជិក ៣០ រូប* | ក្រុមប្រឹក្សារដ្ឋ<br>*សមាជិក ៤២ រូប* |
| គណៈកម្មាការជំនាញ | ក្រុមគម្រោង[២០] | ក្រុមការងារសហព័ន្ធ |
| ក្រុមប្រឹក្សាអាជ្ញាកណ្តាល | -- | គណៈកម្មការអាជ្ញាកណ្តាលសហព័ន្ធ[២១] *សមាជិក ៥ រូប* |

ស្ថាប័នជាតិរបស់ *សហភាពយុវជន* រួមមានសន្និបាតប្រតិភូ គណៈកម្មាធិការគ្រប់គ្រងតំណាងថ្នាក់ក្រោមជាតិ មានសិទ្ធិធ្វើការសម្រេចចិត្តសំខាន់ៗ ពេលអវត្តមានសន្និបាតប្រតិភូ គណៈកម្មាធិការជំនាញលើបញ្ហាជាក់លាក់ និងគាំទ្រដល់គណៈកម្មាធិការគ្រប់គ្រងឬ អង្គភាពថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល។ បន្ថែមលើនេះទៀត គេមានក្រុម សិស្ស *(សហភាពសិស្ស*[២២]*)* ដែលត្រូវបានរៀបចំជាក្រុមការងារសហព័ន្ធឯករាជ្យមួយ។

*យុវជនបៃតង* មានមហាសន្និបាត គណៈកម្មាធិការគ្រប់គ្រង តំណាងថ្នាក់ក្រោមជាតិ ដែលជាក្រុមប្រឹក្សា យោបល់ជូនគណៈកម្មាធិការគ្រប់គ្រង គណៈកម្មាធិការជំនាញឯករាជ្យជាច្រើននិងក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លើសពីនេះ

២០ German: *Bundeskonferenz, Bundesvorstand, Bundesausschuss* and *Projektgruppen.*

២១ German: *Bundeskongress, BundessprecherInnenrat, Länderrat, Bundesarbeitskreise* and *Bundesschiedskommission*.

២២ German: *Schüler Union*.

ទៀត គេមានគណៈកម្មាធិការជាច់ដោយឡែក និងឯករាជ្យចំនួនបួនផ្សេងទៀត ធ្វើការលើផ្នែកហិរញ្ញវត្ថុ ទំនាក់ទំនង ការអប់រំ ស្ត្រីនិងយេនឌ័រព្រមទាំងការសម្របសម្រួលអន្តរជាតិ។ ជាមួយពហុស្ថាប័នបែបនេះ *យុវជនបៃតង* មានរចនាសម្ព័ន្ធស្មុគ្រស្មាញជាងគេ នៅកម្រិតថ្នាក់ជាតិ។

*រូបភាពទី៣៖ ស្ថាប័នជាតិរបស់សហភាពយុវជន និងយុវជនបៃតង*

| | **សហភាពយុវជន** | **យុវជនបៃតង** |
|---|---|---|
| មហាសន្និបាត/ សន្និបាទប្រតិភូ | សន្និបាតអាឡឺម៉ង់ *ប្រតិភូ ២៤០ រូប* | សភាសហព័ន្ធ *សមាជិក ដែលបានចូលរួមទាំងអស់* |
| គណៈកម្មាធិការគ្រប់គ្រង | ក្រុមប្រឹក្សាភិបាលសហព័ន្ធ *សមាជិក ២៣ រូប* | ក្រុមប្រឹក្សាភិបាលសហព័ន្ធ *សមាជិក ១០ រូប* |
| តំណាងថ្នាក់ក្រោមជាតិ | ក្រុមប្រឹក្សាអាល្លឺម៉ង់ *សមាជិក ៤២ រូប* | កិច្ចប្រជុំក្រុមប្រឹក្សារដ្ឋ និង សហព័ន្ធ *សមាជិក ៤២ រូប* |
| គណៈកម្មាការជំនាញ | គណៈកម្មការ គណៈកម្មា-ធិការជំនាញសហព័ន្ធ | ជំនាញការ Fora |
| ក្រុមប្រឹក្សាអាជ្ញាកណ្តាល | តុលាការអាជ្ញាកណ្តាល សហព័ន្ធ *សមាជិក ៥ រូប* | គណៈកម្មការអាជ្ញាកណ្តាល សហព័ន្ធ *សមាជិក ៦ រូប* |

២៣ German: *Deutschlandtag, Bundesvorstand, Deutschlandrat, Kommissionen, Bundesfachausschüsse* and *Bundesschiedsgericht*.

២៤ German: *Bundeskongress, Bundesvorstand, Bundesvorstand-Landesvorstand-Sitzung, Fachforen* and *Bundesschiedsgericht*.

## *រូបភាពទី៤៖ ស្ថាប័នជាតិនៃក្រុមយុវជនបក្សដែលបានស្ទង់មតិ*

| | យុវជន បៃតង | សហភាព យុវជន | យុវជន ឆ្វេងនិយម | យុវជន សង្គមនិយម | យុវជន ប្រជាជន | យុវជន សង្គ្រោះជាតិ |
|---|---|---|---|---|---|---|
| **មហាសន្និបាត សន្និបាទប្រតិភូ** | សភាសហព័ន្ធ *សមាជិកដែលបានចូលរួមទាំងអស់* | សន្និបាត អាល្លឺម៉ង់ *ប្រតិភូ២៤០រូប* | សភាសហព័ន្ធ *ប្រតិភូ២៥០រូប* | សន្និសីទសហ-ព័ន្ធ/ ប្រតិភូ *ចំនួន៣០០រូប* | ក្រុមការងារ យុវជនថ្នាក់ជាតិ *សមាជិក៥រូប* | ក្រុមការងារ យុវជនមជ្ឈឹម *សមាជិក៦៥រូប* |
| **គណៈកម្មការ គ្រប់គ្រង** | ក្រុមប្រឹក្សា ភិបាល សហព័ន្ធ *សមាជិក១០រូប* | ក្រុមប្រឹក្សា ភិបាល សហព័ន្ធ *សមាជិក២៣រូប* | ក្រុមប្រឹក្សា អ្នកនាំពាក្យ សហព័ន្ធ *សមាជិក៧រូប* | ក្រុមប្រឹក្សាភិ-បាលសហព័ន្ធ *សមាជិក៩រូប* | គណៈកម្មាធិការ អចិន្ត្រៃយ៍ *សមាជិក ១៥-២០រូប* | |
| **តំណាងថ្នាក់ ក្រោមជាតិ** | កិច្ចប្រជុំក្រុម ប្រឹក្សារដ្ឋ និងសហព័ន្ធ *សមាជិក៤២រូប* | ក្រុមប្រឹក្សា អាល្លឺម៉ង់ *សមាជិក៤២រូប* | ក្រុមប្រឹក្សារដ្ឋ *សមាជិក៤២រូប* | គណៈកម្មាធិការ សហព័ន្ធ *សមាជិក៣០រូប* | | |
| **គណៈកម្មការ ជំនាញ** | ជំនាញការ Fora | គណៈកម្មការ គណៈកម្មា-ធិការជំនាញ សហព័ន្ធ | ក្រុមការងារ សហព័ន្ធគណៈ កម្មការអាជ្ញា កណ្តាលសហ សហព័ន្ធ[២៧] *សមាជិក៥រូប* | ក្រុមគម្រោង[២៨] | Subdivisions | |
| **គណៈកម្មការ អជ្ញាកណ្តាល** | គណៈកម្មការ អាជ្ញាកណ្តាល សហព័ន្ធ[២៥] *សមាជិក៦រូប* | តុលាការអាជ្ញា កណ្តាល សហព័ន្ធ[២៦] *សមាជិក៥រូប* | | | | |

២៥ German: *Bundeskongress, Bundesvorstand, Bundesvorstand-Landesvorstand-Sitzung, Fachforen* and *Bundesschiedsgericht*.

២៦ German: *Deutschlandtag, Bundesvorstand, Deutschlandrat, Kommissionen, Bundesfachausschüsse* and *Bundesschiedsgericht.*

២៧ German: *Bundeskongress, BundessprecherInnenrat, Länderrat, Bundesarbeitskreise* and *Bundesschiedskommission.*

២៨ German: *Bundeskonferenz, Bundesvorstand, Bundesausschuss* and *Projektgruppen.*

### ១.៣.២ ថ្នាក់ក្រោមជាតិ

ខណៈដែល *យុវជនសង្គមនិយម* នៅថ្នាក់ក្រោមជាតិមានរហូតដល់ទៅប្រាំកម្រិត *ក្រុមយុវជនគណបក្សសង្គ្រោះជាតិ* និង *សហភាពយុវជន* មានបួនកម្រិត *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា* និង *យុវជនបៃតង* មានបី និង *យុវ-ជនឆ្វេងនិយម* មានពីរកម្រិត។ កម្រិតក្រោមជាតិខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា គឺថ្នាក់ខេត្ត និងនៅក្នុងប្រទេសអាល្លឺម៉ង់ គឺកម្រិតរដ្ឋ។ បន្តបន្ទាប់ដោយថ្នាក់ស្រុក អនុស្រុក ឃុំ និងថ្នាក់មូលដ្ឋាន។ គ្រប់ក្រុមយុវជនបក្ស ដែលត្រូវបានស្ទង់មតិយ៉ាងហោចណាស់មានតំណាងរបស់ខ្លួននៅកម្រិតរដ្ឋ ខេត្ត ឃុំសង្កាត់ ឬកម្រិតមូលដ្ឋាន។[២៩]

*រូបភាពទី៥៖ កម្រិតថ្នាក់ក្រោមជាតិនៃក្រុមយុវជនដែលបានស្ទង់មតិ*

| យុវជននិយមឆ្វេង | យុវជនបៃតង | ក្រុមយុវជនបក្សប្រជាជនកម្ពុជា | សហភាពយុវជន | យុវជនគណបក្សសង្គ្រោះជាតិ | យុវជនសង្គមនិយម |
|---|---|---|---|---|---|
| រដ្ឋ | រដ្ឋ | ខេត្ត | រដ្ឋ | ខេត្ត | រដ្ឋ |
| | ស្រុក | ស្រុក | ស្រុក | ស្រុក | ស្រុក |
| | | | | | អនុស្រុក |
| | | ឃុំ | តំបន់ | ឃុំ | តំបន់ |
| ក្រុម | ក្រុង | ភូមិ | ក្រុង | ភូមិ | ក្រុម |

កម្រិតថ្នាក់ក្រោមជាតិរបស់ *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* និង

២៩ ដោយហេតុថាឈ្មោះនៅកម្រិតថ្នាក់ក្រោមជាតិ មិនត្រឹមតែខុសគ្នានៅក្នុងចំណោមក្រុមយុវជនបក្សទាំងប្រាំមួយ ប៉ុន្តែនៅតាមសមាគមថ្នាក់ក្រោមជាតិនីមួយៗផង តារាងនេះគ្រាន់តែអាចផ្តល់នូវទិដ្ឋភាពទូទៅនិងមិនអាចបង្ហាញឈ្មោះដែលត្រូវបានប្រើប្រាស់ទាំងអស់នោះទេ។

*គណបក្សសង្គ្រោះជាតិ* គឺមានភាពស្រដៀង គ្នាទៅនឹងថ្នាក់ជាតិរបស់ខ្លួន ក្រុមការងារត្រូវបានតែងតាំងដោយអំណាចរបស់គណបក្សមេ។ ជាទូទៅ ពួកគេមិនមាន រចនាសម្ព័ន្ធខាងក្នុងណាមួយបន្ថែមទៀតទេ។

ខណៈដែលក្រុមការងារថ្នាក់ក្រោមជាតិរបស់ *ក្រុមយុវជនរបស់គណបក្សប្រជាជនកម្ពុជា* ស្ថិតនៅក្រោមបង្គាប់ ទាំងអំណាចថ្នាក់ខ្ពស់បន្ទាប់ និងអំណាចគណបក្ស ក្រុមការងារថ្នាក់ក្រោមជាតិរបស់ *ក្រុមយុវជនគណបក្សសង្គ្រោះជាតិ* គឺមិនស្ថិតនៅក្រោមការបង្គាប់បញ្ជា របស់ថ្នាក់ខ្ពស់បន្ទាប់ ពោលគឺក្រោមអំណាចបក្សតែមួយប៉ុណ្ណោះ។

ថ្នាក់ក្រោមជាតិរបស់ *យុវជនសង្គមនិយម* ត្រូវបានរៀបចំជាក្រុមការងាររបស់បក្សដែរ ហើយជាទូទៅ រចនាសម្ព័ន្ធ ខាងក្នុងមានលក្ខណៈស្រដៀងគ្នាទៅនឹង កម្រិតថ្នាក់ជាតិ ពោលគឺមហាសន្និបាត/សន្និបាតប្រតិភូ គណៈកម្មាធិការគ្រប់គ្រង និងគណៈកម្មការជំនាញសម្រាប់គាំទ្រ។

ថ្នាក់ក្រោមជាតិរបស់ *សហភាពយុវជន យុវជននិយមឆ្វេង* និង *យុវជនបៃតង* គឺដូចកម្រិតថ្នាក់ជាតិ ពោលគឺឯករាជ្យពីគណបក្សមេរបស់ខ្លួន។ ថ្នាក់ក្រោមជាតិខ្ពស់បំផុត គឺសមាគមរដ្ឋនៃ *សហភាពយុវជន យុវជននិយមឆ្វេង* និង *យុវជនបៃតង* ដែលឯករាជ្យចេញពីថ្នាក់ជាតិរបស់ខ្លួន។ បើទោះជាដូចនេះក្តី រចនាសម្ព័ន្ធខាងក្នុងរបស់ពួកគេ គឺស្រដៀងគ្នាទៅនឹងកម្រិតថ្នាក់ជាតិ។ ជាទូទៅ ចំពោះថ្នាក់ទាបភាគច្រើនមានលទ្ធភាពខ្ពស់ រៀបចំអោយមានមហាសន្និបាតជំនួសឱ្យសន្និបាទគណៈប្រតិភូ ដែលជាអង្គនីតិបញ្ញត្តិកម្រិតសំខាន់។ ក្រុមយុវជនបក្ស ដែលមានមហាសន្និបាត នៅគ្រប់កម្រិតទាំងអស់ គឺ *យុវជនបៃតង*។

ផ្ទុយពីក្រុមការងារនិស្សិតសាកលវិទ្យាល័យសហព័ន្ធ របស់ *យុវជននិយមឆ្វេង សហភាពយុវជន* និង *យុវជនសង្គមនិយម* ដាក់បញ្ចូលក្រុមនិស្សិតសាកលវិទ្យាល័យ ទៅក្នុងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិរបស់ខ្លួន។ *សហភាពយុវជន* មានក្រុមនិស្សិតសាកលវិទ្យាល័មួយចំនួនតូច ជាតួយ៉ាងនៅ Greifswald, Osnabrück និង Kiel ដែលត្រូវបានរៀបចំជាក្រុមការងារតាមកម្រិតផ្សេងៗ

គ្មាននៃ*សហភាពយុវជន*។ ផ្ទុយទៅនឹងសហភាពសិស្ស ពួកគេមិនមានរចនាសម្ព័ន្ធ ថ្នាក់ជាតិណាមួយ ដែលភាគច្រើនវាជាការប្រកួតប្រជែងខាងក្នុងរបស់សមាគមនិស្សិតប្រជាធិបតេយ្យគ្រិស្តសាសនិក*(RCDS)*[៣០]ដែលជាក្រុមនិស្សិតសាកលវិទ្យាល័យឯករាជ្យមួយទៀត ជាប់ទាក់ទងជាមួយ *CDU* ដែលមិនសូវមានជាទូទៅទេ។[៣១] *ក្រុមយុវជនសាកលវិទ្យាល័យសង្គមនិយម*[៣២] ដែលជាក្រុមនិស្សិតសាកលវិទ្យាល័យរបស់*យុវជនសង្គមនិយម* ត្រូវបានរៀបចំជាក្រុមការងារថ្នាក់ស្រុករបស់ *យុវជនសង្គមនិយម*។ បើទោះជាដូចនេះក្តី ពួកគេមានរចនាសម្ព័ន្ធខាងក្នុងរបស់ខ្លួន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១.៤ សមាជិក និងសមាជិកភាព

ជាមួយសមាជិកប្រមាណ ១១៥.០០០នាក់ *សហភាពយុវជន* ច្បាស់ណាស់ជាក្រុមយុវជនបក្សធំ ជាងគេបំផុតក្នុងចំណោមក្រុមទាំងប្រាំមួយ។ បន្ទាប់មកទៀតគឺ *យុវជនសង្គមនិយម* ដែលមានសមាជិកប្រមាណ ៧២.០០០នាក់ *យុវជននិយមឆ្វេង* មានសមាជិកប្រហែល ១០.០០០នាក់ និង*យុវជនបៃតង* មានសមាជិកប្រមាណ ៧.០០០នាក់។ បើទោះជាបែបនេះក្តី ដើម្បីបកស្រាយលេខនេះអោយបានត្រឹមត្រូវ អាយុកំណត់ ព្រមទាំងសមាជិកភាពទ្វេភាគី (សូមមើលជំពូក ១.៤.១) ត្រូវតែយកមកពិចារណា។ ដោយហេតុថា *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* និង*គណបក្សសង្គ្រោះជាតិ* ត្រូវបានដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធរបស់គណបក្សមេដូចនេះ ពួកគេមិនមានគោលនយោបាយសមាជិកភាពផ្ទាល់ខ្លួនទេ។ ដូច្នេះហើយ រហូតមកដល់ឥឡូវនេះ គ្មានស្ថិតិចំនួនសមាជិកជាក់លាក់ ហើយអាយុរបស់សមាជិកភាគច្រើន គ្រាន់តែអាចត្រូវបាន

៣០ German: *Ring Christlich-Demokratischer Studenten (RCDS)*.

៣១ Cf. i. a. Junge Union Nordrhein-Westfalen, Geschäftsordnung für Hochschulgruppen, [http://ju-nrw.de/ju-nrw/satzung/geschaeftsordnung-hochschulgruppen](http://ju-nrw.de/ju-nrw/satzung/geschaeftsordnung-hochschulgruppen) (24.02.2016) and Ring Christlich-Demokratischer Studenten, RCDS Geschichte, [http://rcds.de/geschichte/](http://rcds.de/geschichte/) (24.02.2016).

៣២ German: *Juso Hochschulgruppen.*

ប៉ាន់ប្រមាណតែប៉ុណ្ណោះ។

*ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* អាចជាក្រុមដែលមានសមាជិកចាស់ជាងគេ ក្នុងចំណោមក្រុមទាំងប្រាំមួយ។ ដើម្បីក្លាយជាសមាជិកគណបក្សមេ ពួកគេត្រូវមានអាយុលើស ១៨ឆ្នាំ ប៉ុន្តែមិនមានអាយុដែលកំណត់ខ្ពស់បំផុតទេ។ ជាទូទៅ សមាជិកគឺមានអាយុចន្លោះពី ២៥ឆ្នាំទៅ ៥០ឆ្នាំ ជាមធ្យមអាយុប្រហែល ៣៥ឆ្នាំ។ សមាជិកនៃ *ក្រុមយុវជនគណបក្សសង្គ្រោះជាតិ* ចាំបាច់ត្រូវជាសមាជិកបក្សដែរ មានន័យថាត្រូវមានអាយុលើសពី ១៨ឆ្នាំ។ វាមិនមានអាយុកំណត់ខ្ពស់បំផុតនោះទេ ប៉ុន្តែសមាជិកភាគច្រើនមានអាយុតិចជាង ៣៥ ឆ្នាំ។ ក៏មានផងដែរ អ្នកគាំទ្រក្រៅផ្លូវការដែលមិនមែនជាសមាជិកពិតប្រាកដ ដែលមានអាយុតិចជាង ១៨ឆ្នាំ។ ជាមួយលក្ខខណ្ឌលើកលែងមួយចំនួនសម្រាប់អ្នកកាន់ក្តាប់មុខតំណែង សមាជិករបស់ *សហភាពយុវជន យុវជនសង្គម និយម* និង *យុវជននិយមឆ្វេង* មិនអាចមានអាយុលើស ៣៥ឆ្នាំទេ។

អាយុកំណត់ទាបបំផុត សម្រាប់ក្រុមយុវជនទាំងបីនេះគឺ ១៨ឆ្នាំ។ ក្នុងការស្ទង់មតិនេះ សមាជិកដែលក្មេងជាងគេបំផុត គឺនៅក្នុង*យុវជនបៃតង*។ នៅកម្រិតថ្នាក់ជាតិ សមាជិករបស់ខ្លួន គឺមិនត្រូវមានអាយុលើសពី ២៧ឆ្នាំទេ។ ទោះជាដូចនេះក្តី សមាគមរ ដ្ឋមួយចំនួននៅតែអនុញ្ញាតឱ្យចូលជាសមាជិកបើទោះជាមានអាយុ ២៩ឆ្នាំ ។ នៅគ្រប់កម្រិតទាំងអស់ គឺគ្មានកំណត់អាយុទាបបំផុតទេ មានន័យ ថាបើមានការយល់ព្រមពីឪពុកម្តាយ សូម្បីតែកូនក្មេងក៏អាចក្លាយជាសមាជិកបានដែរ។

### *១.៤.១ សមាជិកភាពជាឯកតោភាគី និងទ្វេភាគី*

សមាជិករប ស់ *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* និង*គណបក្សសង្គ្រោះជាតិ* ត្រូវតែជាសមាជិករបស់គណបក្សមេ សមាជិកភាពទ្វេភាគី ជាការតម្រូវ

ចាំបាច់។[៣៣] សមាជិកគណបក្សដែលមានអាយុចន្លោះកំណត់អាយុជាយុវជនបក្ស អាចសម្រេចចិត្តដោយខ្លួនឯង ថាបើពួកគេចង់ចូលខ្លួនជាសមាជិកក្រុមយុវជនបក្សឬមិនចូល។

សមាជិករបស់ *សហភាពយុវជន យុវជនសង្គមនិយម យុវជននិយមឆ្វេង* និង *យុវជនបៃតង* មិនចាំបាច់ ត្រូវតែជាសមាជិករបស់គណបក្សមេខ្លួន យុវជនបក្សទាំងបួនក្រុមនេះ អនុញ្ញាតឱ្យយុវជនចូលជាសមាជិកទោល និងទ្វេ។ បើទោះជា ដូចនេះក្ដី មានការកំណត់ខុសគ្នាចំពោះសមាជិកបក្សដែលមានអាយុក្នុងដែនកំណត់អាយុយុវជនបក្ស ពោលគឺៈ សមាជិក *SPD* ដែលស្ថិតក្នុងអាយុកំណត់ជា *យុវជនសង្គមនិយម* ត្រូវបានកំណត់ដោយស្វ័យប្រវត្តិជាសមាជិកនៃក្រុមយុវជន បើទោះបីជាវាមិនបានសំដែងចេញមកក៏ដោយ។ ប្រមាណ ៧០% នៃ *យុវជនសង្គមនិយម* ក្នុងពេលដំណាលគ្នាជាសមាជិកនៃ *SPD*។ នៅក្នុងរដ្ឋអាល្លឺម៉ង់ចំនួនប្រាំ[៣៤] *សមាជិកនៃសម្ព័ន្ធ 90/ The Green* ដែលស្ថិតនៅក្នុងអាយុកំណត់ *យុវជនបៃតង* ត្រូវបានចាត់ទុកជាសមាជិកក្រុមយុវ-ជនដោយស្វ័យប្រវត្តិ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋចំនួនដប់មួយផ្សេងទៀត ពួកគេត្រូវបង្ហាញឱ្យបានច្បាស់ ដោយដាក់ពាក្យសុំជាសមាជិក។ សមាជិកនៃ *បក្សឆ្វេងនិយម* ដែលមានអាយុចន្លោះពី ១៤ និង ៣៥ ត្រូវបាន គេចាត់ទុកថាជាសមាជិកអកម្មដោយស្វ័យប្រវត្តិរបស់ *ក្រុមយុវជននិយមឆ្វេង*។ ក្នុងករណីនេះ ពួកគេមានមិនមានសិទ្ធិ និងភារកិច្ចអ្វីទេក្រៅអំពីការទទួលបានព័តមានអំពីសកម្មភាពនិងព្រឹត្តិការណ៍ផ្សេងៗ។ ប៉ុន្តែសមាជិកអកម្ម អាចបង្ក សមាជិកភាពរបស់ខ្លួនវិញបាន ដែលផ្ដល់ឱ្យពួកគេនូវសិទ្ធិបោះឆ្នោត ជាមួយនឹងកាតព្វកិច្ចបង់ថ្លៃសមាជិកភាព។ សមាជិក *CDU* ដែលមានអាយុក្នុងដែនកំណត់សហ-ភាពយុវជន ចាំបាច់ត្រូវដាក់ពាក្យសុំសមាជិកភាពជាផ្លូវការ ប្រសិនបើពួកគេចង់ក្លាយជាសមាជិក។

---

៣៣ ខណៈដែលសមាជិកភាព ទ្វេភាគបញ្ជាក់ថាមនុស្សម្នាក់គឺជាសមាជិកបក្សផង និងក្រុមយុវជនបក្សផង ហើយសមាជិកទោល មានន័យ ថាមនុស្សម្នាក់គឺគ្រាន់តែជាសមាជិកនៃក្រុមយុវជនឬគណបក្សមេ។

៣៤ ទីក្រុងបារ៉ាំង, ទីក្រុង Hamburg, Hess, North Rhine Westphalia និង Thuringia។

### *១.៤.២ សិទ្ធ និងកាតព្វកិច្ចរបស់សមាជិក*

ដូចគ្នានឹងសមាជិកភាពនៅក្នុងសមាគមផ្លូវការផ្សេងទៀតណាដែរ សមាជិកភាពក្នុងក្រុមយុវជនបក្សភ្ជាប់មកជាមួយនូវសិទ្ធិនិងកាតព្វកិច្ច។ សិទ្ធិរួមមាន សិទ្ធិក្នុងការបោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោត ព្រមទាំងសិទ្ធិចូលរួមក្នុងព្រឹត្តិការណ៍របស់ក្រុមយុវជនផងដែរ។ កាតព្វកិច្ចសាកល រួមទាំងការអនុវត្តតាមបទប្បញ្ញត្តិផ្ទៃក្នុងរបស់ក្រុមយុវជនបក្ស និងកាតព្វកិច្ចត្រូវបង់ថ្លៃសមាជិកភាពទៀងទាត់។

ចំណុចនេះ គឺមានខុសប្លែកគ្នាយ៉ាងច្រើនក្នុងចំណោមយុវជនបក្សទាំងប្រាំមួយក្រុម ដែលយើងបានកត់សម្គាល់៖ អ្នកកាន់ការរបស់ *ក្រុមយុវជនគណ-បក្សប្រជាជនកម្ពុជា* និង*យុវជនគណបក្សសង្គ្រោះជាតិ* ជាធម្មតាមិនត្រូវបានបោះឆ្នោតជ្រើសរើស ប៉ុន្តែត្រូវបានតែងតាំង តាមរយៈអំណាចបក្សរៀងៗខ្លួន ខណៈដែល*សហភាពយុវជន យុវជនសង្គមនិយម យុវជននិយមឆ្វេង* និង*យុវ-ជនបៃតង* ជាទូទៅត្រូវបានបោះឆ្នោតជ្រើសរើស ក្នុងចំណោមតំណាងរបស់ពួកគេឧទាហរណ៍ នៅក្នុងគណៈកម្មាធិការគ្រប់គ្រង របស់គណបក្សមេ ឬសាធារណជនទូទៅ។

លើសពីនេះទៅទៀត ដោយហេតុថា *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ* និង*យុវជនសង្គមនិយម* ជាអនុផ្នែករបស់គណបក្សមេ ពួកគេមិនប្រមូលថ្លៃសមាជិកភាពទេ ធ្វើឱ្យពួកគេពឹងផ្អែកលើការផ្តល់ថវិកាពីគណបក្ស និងម្ចាស់ជំនួយផ្សេងទៀត។ ផ្ទុយទៅវិញជាក្រុមយុវជនឯករាជ្យ ទាំង*សហភាពយុវជន យុវជននិយមឆ្វេង* និង*យុវជនបៃតង* ប្រមូលថ្លៃសមាជិកភាព។ ជាញឹកញយ វាអាស្រ័យលើស្ថានភាពហិរញ្ញវត្ថុរបស់សមាជិក និងជាធម្មតាចាប់ពី ១០អឺរ៉ូ ទៅ ២០អឺរ៉ូ ក្នុងមួយឆ្នាំ។ ខណៈដែល *សហភាពយុវជន* ប្រមូលថ្លៃសមាជិកភាពរបស់ខ្លួននៅថ្នាក់ក្រោមជាតិ បន្ទាប់មកបានផ្ទេរចំណែកណាមួយទៅកាន់ស្ថាប័នថ្នាក់ជាតិ យុវជននិយមឆ្វេង និង*យុវជនបៃតង* ប្រមូលថ្លៃសមាជិកភាពរបស់ខ្លួន នៅថ្នាក់ជាតិ បន្ទាប់មកផ្ទេរមួយចំណែកទៅ

ថ្នាក់ក្រោមជាតិ។ យើងក៏បានសង្កេតឃើញផងដែរថា សមាជិក *ក្រុមយុវជនបក្សប្រជាជនកម្ពុជា* និង*បក្សសង្គ្រោះជាតិកម្ពុជា* ហាក់បីដូចជាមានសិទ្ធិ និងកាតព្វកិច្ចតិចតួចជាងសមាជិក នៃ*សហភាពយុវជន យុវជននិយមឆ្វេង យុវ-ជនបៃតង* និង*យុវជនសង្គមនិយម*។

## ២. ក្របខណ្ឌគោលនយោបាយនៃយុវជនគណបក្សនយោបាយ ដែលត្រូវបានធ្វើការអង្កេត

ជំពូកនេះ ពិភាក្សាយ៉ាងសង្ខេបពីក្របខណ្ឌនយោបាយ របស់ក្រុមយុវជនបក្ស ដែលបានស្ទង់មតិ ក៏ដូចជាដំណើរការ និងការអភិវឌ្ឍន៍របស់ពួកគេ។ គោលនយោបាយរបស់ក្រុមយុវជនបក្សភាគច្រើន មិនត្រឹមតែផ្តោតលើប្រធានបទដូចជាការអប់រំ និងការចូលរួមរបស់យុវជនប៉ុណ្ណោះទេ ប៉ុន្តែលើប្រធានបទពាក់ព័ន្ធ និងនយោបាយទូទៅផងដែរ។ ក្នុងករណីជាច្រើន ពួកគេផ្តោតការគិតគូរលើយុវជន ដែលពេលខ្លះអាចខុសប្លែកលើវិស័យមួយចំនួន ពីក្របខណ្ឌគោលនយោបាយរបស់គណបក្សមេ។ ប្រធានបទសំខាន់ៗ របស់ក្រុមយុវជនបក្សមាន៖

- *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* - ការអប់រំ ការងារ និងការថែទាំសុខភាព
- *ក្រុមយុវជនគណបក្សសង្គ្រោះជាតិ* - ការអប់រំ សិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- *សហភាពយុវជន* - ការអភិវឌ្ឍសេដ្ឋកិច្ច គ្រួសារនិងការអប់រំ
- *យុវជនសង្គមនិយម* - យុត្តិធម៌សង្គម សមភាពយេនឌ័រ និងការអប់រំ
- *យុវជននិយមឆ្វេង* - ប្រជាធិបតេយ្យចំពោះ សមភាពយេនឌ័រ និងការអប់រំ
- *យុវជនបៃតង* - ការការពារបរិស្ថាន សមភាពយេនឌ័រនិងការអប់រំ។

ដូចដែលបានមើលឃើញប្រធានបទទាំងនេះជាច្រើន គឺត្រួតលើគ្នា ជាពិសេសការអប់រំ គឺជាបញ្ហាដែលក្រុមយុវជនបក្សទាំងអស់ បានយកចិត្តទុកដាក់ជាពិសេស។[៣៥]

---

៣៥ ដោយហេតុថាការបង្កើតកម្មវិធីនយោបាយរបស់ក្រុមយុវជនបក្ស ត្រូវបានធ្វើឡើងក្នុងរចនាសម្ព័ន្ធខាងក្នុងសូមស្វែងយល់បន្ថែមក្នុងជំពូកនេះ ផ្អែកលើមូលដ្ឋានក្នុងជំពូកដំបូង។

## ២.១ តួនាទីចំពោះគណបក្សមេ

ក្នុងនាមជាអ្នកអនុម័តកម្មវិធីនយោបាយរបស់ខ្លួន មានន័យថាពួកគេអាចលើកឡើងពីភាពខុសប្លែកគ្នាតិចតួចជូនគណបក្សមេ ក្នុងនេះ *ក្រុមយុវជនគណបក្សប្រជាជនកម្ពុជា* និង *គណបក្សសង្គ្រោះជាតិ* ដែលត្រូវបានគេមើលឃើញថា ជាផ្នែកមួយដ៏សំខាន់របស់ "ក្រុមគ្រួសារគណបក្ស" មិនមានជាក្របខណ្ឌនយោបាយផ្ទាល់ខ្លួនទេ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានការឯកភាពគ្នា ពួកគេបានត្រឹមតែលើកកម្ពស់គោលនយោបាយគណបក្សមេខ្លួនតែប៉ុណ្ណោះ។

*សហភាពយុវជន យុវជនសង្គមនិយម យុវជននិយមឆ្វេង* និង *យុវជនបៃតង* ជាទូទៅគាំទ្រដល់គណបក្សមេ បើទោះជាដូចនេះក្តី ពួកគេមិនស្ទាក់ស្ទើរក្នុងការលើកឡើងពីភាពខុសគ្នា ទាក់ទងនឹងកម្មវិធីនយោបាយរបស់ខ្លួន ឧទាហរណ៍ ប្រាក់ឈ្នួលអប្បបរមា ដែលបានដាក់ចេញថ្មី ការរក្សាទុកទិន្នន័យរបស់រដ្ឋាភិបាល ការកាត់បន្ថយអាយុបោះឆ្នោត និងសេចក្តីប្រកាសនៃប្រទេសដែលមានសុវត្ថិភាពសម្រាប់ជនភៀសខ្លួន។

ក្របខណ្ឌនៃការរីកវាលដាលក្នុងចំណោមក្រុមយុវជនបក្សគឺ "ចំណងសាមគ្គីភាពរឹងមាំ" - ភាពខុសគ្នារវាងក្រុមយុវជនបក្ស និងគណបក្សមេ អាស្រ័យលើបញ្ហានិងស្ថានភាពទូទៅការពិភាក្សាផ្ទៃក្នុង និងជាសាធារណៈ។ ក្នុងនោះដែរ មតិ រិះគន់ជាសាធារណៈរបស់ក្រុមយុវជន អាចធ្វើឡើងដោយផ្ទាល់[៣៦] ប៉ុន្តែភាគច្រើនវាទទួលបានលទ្ធផល។ ជាឧទាហរណ៍ នៅកម្រិតថ្នាក់ជាតិ ការអនុម័ត

---

៣៦ Cf. i. a. N. N., Breitseite gegen Merkel. Junge Union wirft CDU Ideenlosigkeit vor, at: FAZ.net, 03.03.2015, http://www.faz.net/aktuell/politik/inland/junge-union-kritisiert-cdu-fuer-fehlende-themen-13460433.html (26.02.2015), Dietmar Neuerer, Streit in der SPD. Juso-Chefin gegen Vorratsdatenspeicherung, at: Handelsblatt.com, 17.01.2015, http://www.handelsblatt.com/politik/deutschland/streit-in-der-spd-juso-chefin-gegen-vorratsdatenspeicherung/11243252.html (26.02.2016), and Lisa Caspari, Parteitag. Das Flüchtlingsproblem verfolgt die Grünen, at: Zeit.de, 22.11.2014, http://www.zeit.de/politik/deutschland/2014-11/gruene-parteitag-fluechtlinge/komplettansicht (26.02.2016).

លើការសើរើឡើងវិញរបស់ *សហភាពយុវជន* ដើម្បីដាក់បញ្ចូលភ្លេងជាតិទៅក្នុងច្បាប់មូលដ្ឋានរបស់អាល្លឺម៉ង់ ដោយ *CDU* អំឡុងសន្និសិទគណបក្សសហព័ន្ធនៅក្នុងខែធ្នូ ឆ្នាំ២០១៥[៣៧] និងការស្នើពិនិត្យឡើងវិញ លើពន្ធអចលនទ្រព្យ *យុវជនសង្គមនិយម* តាមរយៈសន្និសីទគណបក្សសហព័ន្ធ *SPD* នៅខែវិច្ឆិកា ឆ្នាំ២០០៩។[៣៨] នៅលើកម្រិតថ្នាក់ក្រោមជាតិ *យុវជននិយមឆ្វេង* ទទួលបានជោគជ័យឧទាហរណ៍ ចលនា ឬការស្នើអោយមានការផ្តល់សំបុត្រឥតគិតថ្លៃសិស្ស សម្រាប់ការដឹកជញ្ជូនសាធារណៈ[៣៩] និងចលនារបស់ *យុវជនបៃតង* ដើម្បីបញ្ចប់កិច្ចព្រមព្រៀង លើកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ និងកងកម្លាំងប្រដាប់អាវុធ។[៤០] ការអនុម័តលើចលនា/ការស្នើរឡើងទាំងនេះ រួមទាំងការដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់គណបក្សនីមួយៗ បានបង្ហាញពីសារៈសំខាន់របស់ក្រុមយុវជនបក្ស សម្រាប់ការអភិវឌ្ឍគោលនយោបាយគណបក្សមេ។

## ២.២ ការតាក់តែងគោលនយោបាយផ្ទាល់ខ្លួន

ដើម្បីអាចលើកឡើងនូវសំណើបែបនេះ ក៏ដូចជាអនុវត្តគោលនយោបាយតាម

៣៧ Cf. i. a. N. N., CDU-Parteitag. CDU will Nationalhymne im Grundgesetz verankern, at: Zeit.de, 15.12.2015, *http://www.zeit.de/politik/deutschland/2015-12/cdu-parteitag-angela-merkel-grundgesetz-nationalhymne* (26.02.2016).

៣៨ Cf. i. a. N. N., Überraschung auf Parteitag. SPD will Vermögensteuer zurück, at: Spiegel.de, 14.11.2009, *http://www.spiegel.de/politik/deutschland/ueberraschung-auf-parteitag-spd-will-vermoegensteuer-zurueck-a-661338.html* (26.02.2016).

៣៩ Cf. i. a. Linksjugend Solid Frankfurt a. M., Parteitag aktuell. solid Anträge angenommen, *http://www.solid-frankfurt.de/ak-kommunales/parteitag-aktuell-solid-antrage-angenommen* (26.02.2016).

៤០ Cf. i. a. Grüne Jugend Baden-Württemberg, "Schulfrei für die Bundeswehr". Parteitag bestätigt Forderung der Grünen Jugend, 02.12.2012, *https://www.gjbw.de/schulfrei-fur-die-bundeswehr-parteitag-bestatigt-forderung-der-grunen-jugend/* (26.02.2016).

